ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ចំណុះផ្ទាល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទាំង ៦ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ
- តាមសំណើររបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

# សម្រេច

**មាត្រា ១.–**

បង្កើតមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ហៅកាត់ថា **ម.ធ.អ.ក** ចំណុះផ្ទាល់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មានឋានៈស្មើប្រធាននាយកដ្ឋាន។

**មាត្រា ២.–**

មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា មានមុខងារ និងភារកិច្ចដូចខាងក្រោមៈ

– ផ្លាស់ប្ដូរ និងផ្សព្វផ្សាយព័ត៌មាន អំពីវិស័យមុខងារសាធារណៈជាមួយបណ្ដាជ្ឈមណ្ឌលធនធានអាស៊ាននៃប្រទេសសមាជិកអាស៊ាន។
– គ្រប់គ្រងព័ត៌មាន និងឯកសារដែលទាក់ទងនឹងវិស័យមុខងារសាធារណៈអាស៊ាន
– រៀបចំឯកសារ និងស្នើសុំយោបល់សម្រេចពីគណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកមុខងារសាធារណៈក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងអាស៊ាន មានជាអាទិ៍ ផែនការបណ្ដុះបណ្ដាលបង្កើនសមត្ថភាពមន្ត្រីរាជការស៊ីវិល ការចូលរួមប្រជុំ និងសកម្មភាពជំនាញផ្នែកមុខងារសាធារណៈ
– សហការជាមួយលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា អំពីកិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យមុខងារសាធារណៈ
– លើកគម្រោងផែនការចំណាយសម្រាប់សកម្មភាពរបស់មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា
– ធ្វើរបាយការណ៍អំពីសកម្មភាពការងារជូនថ្នាក់ដឹកនាំនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារសាធារណៈ និងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា។

**មាត្រា ៣.–**

មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ដឹកនាំដោយប្រធាន ១ រូប និងមានអនុប្រធានជាជំនួយការ តាមការចាំបាច់។

**មាត្រា ៤.–**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ មជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៥.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

***កន្លែងទទួល***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ–កាលប្បវត្តិ